**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៨/០១៧ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៨៩ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលប្រព័ន្ធបៀវត្សរបស់មន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការកែសម្រួលបៀវត្សមូលដ្ឋាននិងការបើកផ្តល់បៀវត្សដល់មន្ត្រីនគរបាលជាតិកម្ពុជា



9

- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងការដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១ .-**

ប្រាក់បំណាច់មុខងារមន្ត្រីនគរបាលជាតិកម្ពុជា ត្រូវបានកែប្រែនិងដំឡើងដូចខាងក្រោម៖

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១ | អគ្គស្នងការ | ១ ៨៣០ ០០០ |
| ២ | អគ្គស្នងការរង | ១ ៤៨០ ០០០ |
| ៣ | ប្រធាននាយកដ្ឋាន | ៨១០ ០០០ |
| ៤ | អនុប្រធាននាយកដ្ឋាន | ៧៤០ ០០០ |
| ៥ | នាយការិយាល័យចំណុះនាយកដ្ឋាន | ៦១០ ០០០ |
| ៦ | នាយរងការិយាល័យចំណុះនាយកដ្ឋាន | ៥៤០ ០០០ |
| ៧ | នាយផ្នែកចំណុះនាយកដ្ឋាន | ៤៨០ ០០០ |
| ៨ | នាយរងផ្នែកចំណុះនាយកដ្ឋាន | ៤៤០ ០០០ |
| ៩ | នាយប៉ុស្តិ៍នគរបាលរដ្ឋបាល | ៤២០ ០០០ |
| ១០ | នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាល | ៤១៥ ០០០ |
| ១១ | នាយរងប៉ុស្តិ៍នាយកដ្ឋាននគរបាលការពារ | ៤១០ ០០០ |
| ១២ | នាយក្រុមនគរបាលពន្លត់អគ្គីភ័យចំណុះនាយកដ្ឋាន | ៤០០ ០០០ |
| ១៣ | នាយរងក្រុមនគរបាលពន្លត់អគ្គីភ័យចំណុះនាយកដ្ឋាន | ៣៩៥ ០០០ |
| ១៤ | នាយក្រុមនគរបាលការពារចំណុះរាជធានី ខេត្ត | ៣៩០ ០០០ |
| ១៥ | នាយរងក្រុមនគរបាលការពារចំណុះរាជធានី ខេត្ត | ៣៨៥ ០០០ |
| ១៦ | មន្ត្រីនគរបាលជាតិ | ៣៨០ ០០០ |

**មាត្រា២ .-**

ប្រាក់បំណាច់មុខងារខាងលើ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ តទៅ។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៣ កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ